# **របាយការណ៍សង្ខេប**

## **ស្តីពី**

## «**ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២)**» **របស់រដ្ឋបាលខេត្តកំពង់ចាម**»

## **ក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការគណៈរដ្ឋមន្ត្រី**

## **របស់ឯកឧត្តម អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម**

ថ្ងៃព្រហស្បតិ៍ ១២កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ត្រូវនឹងថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ជាទីសក្ការៈ!
- សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងព្រះមហាក្សត្រី **មុនិនាថ សីហនុ** ព្រះវររាជមាតាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!
- សូមគោរព សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!
- សូមគោរពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ***ជាទីគោរពដ៏ខ្ពង់ខ្ពស់ !***
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសន្និសីទសារព័ត៌មាន នាពេលនេះ ***ជាទីមេត្រី !***
- បងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់ ***ជាទីគោរពស្រលាញ់រាប់អាន!***

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មានស្តីពី «**ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ចាម**» និងសូមអរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលបានចូលរួមក្នុងសន្និសីទនេះ។

ក្នុងនាមរដ្ឋបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋខេត្តកំពង់ចាមទាំងមូល ខ្ញុំសូមយកឱកាសនេះសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការដាក់ចេញនូវ កម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ខេត្តកំពង់ចាមបាននឹងកំពុងមានការរីកចម្រើន និងប្រែប្រួលមុខមាត់ជាបន្តបន្ទាប់ទាំងផ្នែកសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងសមិទ្ធផលរូបវន្តជាច្រើន ពិសេសជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែលើកកម្ពស់ពីមួយថ្ងៃទៅមួយថ្ងៃ ក្រោមដំបូលនៃសុខសន្តិភាព។ ខ្ញុំបាទ សូមរាយការណ៍ដោយសង្ខេបអំពី វឌ្ឍនភាព និងសមិទ្ធផលក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ចាមជូនអង្គពិធីជ្រាបដូចខាងក្រោម៖

## I-អំពីលក្ខណៈភូមិសាស្ត្រ និងស្ថានភាពទូទៅ

| | |
|---|---|
| ឈ្មោះក្រុង | កំពង់ចាម |
| សរុបផ្ទៃដីខេត្ត | ៤.៥៤៨,០៩គីឡូម៉ែត្រការ៉េ |
| ស្ថានភាពដី | ចែកជាបីៈ តំបន់ដងទន្លេ, វាលទំនាប និងខ្ពង់រាប |
| សរុបចំនួនប្រជាជន | ១.១៣៤.២២១នាក់ ស្រីចំនួន ៥៧៥.៣៥៨នាក់ |
| សរុបគ្រួសារ | ២៨៤.៣៨៩គ្រួសារ |
| ដង់ស៊ីតេប្រជាជន | ២៤៥នាក់/គ.ម$^{២}$ ទំហំគ្រួសារគិតជាមនុស្ស ៤នាក់ |
| ប្រជាជនមានអាយុ១៨ឆ្នាំឡើង | ៧៥៨.៣៤៥នាក់ ស្រីចំនួន ៣៩២.៩៥២នាក់ |
| ចំនួនរដ្ឋបាលក្រុង/ស្រុក ឃុំ/សង្កាត់ ភូមិ | ៩ស្រុក និងក្រុង១ មាន១០៥ឃុំ និងសង្កាត់៤ ស្មើនឹង៩២៣ភូមិ |
| មុខរបរ | ប្រជាជនប្រកបរបរកសិកម្មជាចម្បងស្មើនឹង ៦៣,៩៣%, របរឧស្សាហកម្ម និងសិប្បកម្ម ០,៦៩% និងរបរសេវាកម្ម ៣៥,៣៨% |
| ព្រំប្រទល់ខេត្ត | ខាងជើងជាប់ខេត្តកំពង់ធំ, ខាងត្បូង ជាប់ខេត្តកណ្ដាល និងខេត្តព្រៃវែង, ខាងកើតជាប់ខេត្តក្រចេះ និងត្បូងឃ្មុំ, និងខាងលិចជាប់ខេត្តកំពង់ឆ្នាំង។ |

-សក្តានុពលសេដ្ឋកិច្ចរបស់ខេត្តកំពង់ចាមពឹងផ្អែកលើវិស័យសំខាន់ៗចំនួន៣ គឺវិស័យកសិកម្ម សេវាកម្ម និងវិស័យឧស្សាហកម្ម ក្នុងនោះ

**១-វិស័យកសិកម្ម** មានទំហំ ៣.១៣៣.៧២១,៩ លានរៀល និងមានចំណែក៤១,១% នៃសេដ្ឋកិច្ចខេត្ត និងកំណើនពី៣,៦% ទៅ៤% ក្នុងឆ្នាំ២០២១ ដែលក្នុងនោះដំណាំមានកំណើនថេរ ៤,៤% ការចិញ្ចឹមសត្វ មានកំណើនពី២,៨% ទៅ ៣,៥% ផលផលនេសាទ មានកំណើនពី២,៤% ទៅ៣,៥% និងរុក្ខាប្រមាញ់ មាន១,៤%ថេរ។

**២-វិស័យឧស្សាហកម្ម** មានទំហំ ១.៦៨៦.៥៩៣លានរៀល និងមានចំណែក២១,២% នៃសេដ្ឋកិច្ចខេត្ត និងមានកំណើន ១១,៣% ដែលក្នុងនោះរ៉ែមានកំណើន ១៨,៤% កម្មន្តសាល ១២,៩% អគ្គីសនី ៣% ទឹកស្អាត១,៩% និងសំណង់ ១,៨%។

**៣-វិស័យសេវាកម្ម** មានទំហំ ២.៥៧២.៤២២,៤លានរៀល និងមានចំណែក៣៧,៧% នៃសេដ្ឋកិច្ចខេត្ត និងមានការថយចុះ៥,៩% ដែលក្នុងនោះលក់ដុំលក់រាយមានការថយចុះ ៧,៥% សណ្ឋាគារ និងភោជនីដ្ឋានថយចុះ១២,៥% រដ្ឋបាលសាធារណៈមានកំណើន ១៤,៦% ហិរញ្ញវត្ថុមានកំណើន ៣% និងសេវាកម្មផ្សេងទៀតថយចុះ៨,២%

-ទំហំសេដ្ឋកិច្ចរបស់ខេត្តកំពង់ចាម សរុបប្រមាណ **៧.៣៩២.៧៣៨លានរៀល** (ប្រាំពីរលានបីរយកៅសិបពីរពាន់ប្រាំពីរយសាមសិបប្រាំបីលានរៀលគត់) គិតជាដុល្លា **១.៨០៥លានដុល្លា** (អត្រាប្តូរប្រាក់ ៤.០៩៦រៀល) ស្មើនឹង៦,៧%នៃសេដ្ឋកិច្ចជាតិសរុប ចំណូលសម្រាប់មនុស្សម្នាក់មានចំនួន **១.៥៩២** ដុល្លា។ សេដ្ឋកិច្ចខេត្តកំពង់ចាម មានកំណើន ៨,៥% នៅឆ្នាំ ២០១៨ ៥,១% និងធ្លាក់ចុះដោយសារវិបត្តិកូវីដ-១៩ ឆ្នាំ២០២០ (-១,១%) និងកើនឡើង ១,៣% ក្នុងឆ្នាំ២០២១។

## II-អំពីវឌ្ឍនភាពការងារ និងសមិទ្ធផល

### ១-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់បានរួមសុខទុក្ខជាមួយប្រជាពលរដ្ឋ និងយកចិត្តទុកដាក់ក្នុងការថែរក្សា សន្តិសុខ សុវត្ថិភាព មានវិធានការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវសកម្មភាព ប៉ុនប៉ងធ្វើរដ្ឋប្រហារពីសំណាក់ពួកឧទ្ទាមក្រៅច្បាប់ និងចលនាបដិវត្តពណ៌ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ការបំផ្លិចបំផ្លាញធនធានធម្មជាតិ ។ល។ បន្ថែមពីនេះ មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ បានចូលរួមយ៉ាងស្រស្រាក់ស្រស្រាំង ក្នុងការប្រយុទ្ធប្រឆាំងនឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងបានចូលរួមអនុវត្តយ៉ាងម៉ឺងម៉ាត់បទបញ្ជា ការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ ក្នុងការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋ ក្នុងពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៦ និងរក្សាសន្តិសុខសណ្តាប់ធ្នាប់ក្នុងពេលដែលកម្ពុជាជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ាន និងកិច្ចប្រជុំសំខាន់ៗដែលមានថ្នាក់ដឹកនាំលើពិភពលោកអញ្ជើញចូលរួម។

តាមរយៈការដាក់ចេញនូវវិធានការសមស្របតាមគោលការណ៍ច្បាប់ ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាប បទល្មើសគ្រប់ប្រភេទ ដោយបានអនុវត្តយ៉ាងសកម្មនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ជាលទ្ធផលខេត្តកំពង់ចាមបានទទួលជ័យ លាភីចំណាត់ថ្នាក់លេខ១ លើចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពទូទាំងប្រទេសចំនួន ៦ឆ្នាំជាប់គ្នា តាំងពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០២០។ លទ្ធផលល្អនេះ គឺបានមកពីការខិតខំរួមគ្នារវាងកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់មន្ត្រីរាជការ និងមានការចូលរួមគាំទ្រពីប្រជាពលរដ្ឋ ព្រមទាំងអនុវត្តតាមយ៉ាងផុលផុសផងដែរ ។

**២-វិស័យអប់រំ ៖**

ផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល បច្ចុប្បន្នខេត្តមានគ្រឹះស្ថានសិក្សា ៥២៩កន្លែង ឃុំ-សង្កាត់មួយ មានអនុវិទ្យាល័យ១កន្លែង មាន១០៨ឃុំ-សង្កាត់ស្មើនឹង៩៩%។ អគារសិក្សាសរុបចំនួន ១.២២៩ខ្នង ស្មើនឹង៧.០៣៦បន្ទប់ ក្នុងនោះអគារសិក្សា ទីចាត់ការ និងអគារស្នាក់នៅដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សរុបចំនួន ៣៧៦ខ្នង ស្មើនឹង២,៣៦៥បន្ទប់ (គិតត្រឹមឆ្នាំ២០២២) ។

**ក-មត្តេយ្យសិក្សា** ចំនួន ២៨៣កន្លែង ក្នុងនោះ សាលាមត្តេយ្យដាច់ដោយឡែកចំនួន ០៦កន្លែង មត្តេយ្យក្នុងបឋមចំនួន ២៧៧កន្លែង។

**ខ-បឋមសិក្សា** ចំនួន ៣៦៩កន្លែង

**គ-មធ្យមសិក្សា** ចំនួន១២៤កន្លែង ក្នុងនោះ អនុវិទ្យាល័យ ចំនួន ៨១កន្លែង និងវិទ្យាល័យចំនួន ៤៣កន្លែង។

ឃ-**គ្រឹះស្ថានឧត្តមសិក្សា** ចំនួន១០កន្លែង គ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៣កន្លែង និងឯកជន៦កន្លែង

**៣-វិស័យការងារ៖**

ខេត្តកំពង់ចាម មានសហគ្រាសគ្រឹះស្ថាន សរុប៤៦៣គ្រឹះស្ថាន ដែលបានស្រូបយកកម្លាំងកម្មករ និយោជិត សរុប៤៤.៦៣៥នាក់ ស្រីចំនួន ៣៤.៣៦០នាក់ ក្នុងនោះ រោងចក្រកាត់ដេរ និងដេរ

ស្បែកជើង ចំនួន២២កន្លែង (នៅស្រុកបាធាយ ជើងព្រៃ ព្រៃឈរ កងមាស កំពង់សៀម និងក្រុងកំពង់ចាម) មានកម្មករ-កម្មការិនីចំនួន ៣២.៤៥៣នាក់ (ស្រី ២៩.៤០៥នាក់)។

នៅទូទាំងខេត្ត សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សរុប ៨២កន្លែង ក្នុងនោះ សាលារដ្ឋ ចំនួន ៨ កន្លែង និងសាលាឯកជន ចំនួន ៧៤កន្លែង

- បានផ្តល់សៀវភៅការងារ ប័ណ្ណការងារដល់កម្មករ ចំនួន ១៩.៣៥០នាក់

## ៤-វិស័យពាណិជ្ជកម្ម៖

- បានធ្វើការស្រាវជ្រាវរកផលិតផលសក្តានុពលខេត្ត នៅតាមបណ្តាក្រុង-ស្រុក ក្នុងគោលបំណងជំរុញចលនាភូមិ១ផលិតផល១ និងលើកស្ទួយផលិតខ្មែរ និងបានណែនាំអំពីតម្រូវការទីផ្សារ ហើយជួយរចនាសំបកវេចខ្ចប់ ស្លាកសញ្ញាមួយចំនួន។
- ក្រុមហ៊ុនដែលបានចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ដែលមានទីស្នាក់ការនៅ ខេត្តកំពង់ចាម ចំនួន ១២៩ ក្នុងនោះក្រុមហ៊ុនឯកជន ២២ និងសហគ្រាស ១០៧។
- ចងក្រងគ្រួសារកសិករចំនួន ១៦៣ក្រុម មានសមាជិក ៧.០០៦នាក់ ក្នុងនោះ ក្រុមផលិតផលស្រូវ ៧០ក្រុម មានសមាជិក ៤.០០០នាក់ ក្រុមផលិតផលដំឡូងមី ១៧ក្រុម មានសមាជិក ៨៥៦នាក់ ក្រុមផលិតមាន់ ៣២ក្រុម មានសមាជិក ៨៤៥នាក់ និងក្រុមផលិតផលបន្លែ ៤៤ក្រុម មានសមាជិក ១.៣០៥នាក់។

## ៥-វិស័យសាធារណការ និងអភិវឌ្ឍន៍ជនបទ ៖

### ៥.១-<u>វិស័យសាធារណការ</u>

មករយៈពេល ៥ឆ្នាំ កន្លងទៅនេះ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត បានអនុវត្តលើវិស័យរបស់ខ្លួន ដោយសម្រេចបានលទ្ធផលគួរជាទីមោទនៈបំផុត ដែលជាអាទិមាន ៖ កសាងផ្លូវក្រាលកៅស៊ូប្រភេទ (AC/DBST) ប្រវែង ១.៨៧៦,៥៨គ.ម ស្ពានបេតុង ប្រវែង ២២.៤០៤ ម៉ែត្រ ផ្លូវក្រួសក្រហមប្រវែង ៩០,៨២គ.ម ស្ពានបេឡេត៍ ២.១៧៥ម៉ែត្រ ប្រឡាយប្រវែង ៧៨.៩០០ម និងលូបង្ហូរទឹកគ្រប់ប្រភេទ ២០.៤០១ម៉ែត្រ ។ បានសាងសង់ថ្មី ឬលើកម្រិត ផ្លូវក្រាលកៅស៊ូប្រភេទ (AC/DBST) ប្រវែង ១៣,៧៨គ.ម ផ្លូវបេតុងប្រវែង ៣,១៥គ.ម ស្ពានបេតុង ប្រវែង ១០០ម៉ែត្រ និងលូបង្ហូរទឹកគ្រប់ប្រភេទ ប្រវែង ៦៦ម៉ែត្រ ។ យើងបានធ្វើការថែទាំខួប និងជួសជុលបន្ទាន់លើផ្លូវក្រាលកៅស៊ូ ផ្លូវបេតុង ផ្លូវកំទេចថ្ម ស្ពានបេឡេត៍ លូបង្ហូរទឹកគ្រប់ប្រភេទ ជាប្រចាំ បន្ថែមពីនេះ យើងក៏មានការងារជួសជុលក្រោយទឹកជំនន់ផងដែរ។

### ៥.២-<u>ការងារអភិវឌ្ឍន៍ជនបទ</u>

ដើម្បី ចូលរួមក្នុងការអភិវឌ្ឍ លើវិស័យហេដ្ឋារចនាសម្ព័ន្ធក្នុងជនបទ រដ្ឋបាលខេត្ត បានសហការជាមួយក្រសួងអភិវឌ្ឍជនបទ តាមរយៈ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាល ក្នុងដំណាក់កាលទី ៤ ប្រកបដោយចីរភាព ជាពិសេស ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការងារផ្គត់ផ្គង់ទឹកស្អាតជនបទ។ ក្នុងរយៈពេល ៥ឆ្នាំនេះ គម្រោង និងសកម្មភាពផ្លូវ ដែលអនុវត្តបានមាន ៖ កសាងផ្លូវកៅស៊ូ ២ជាន់ ប្រវែង១៨៧,៣០

គ.ម។ សាងសង់ផ្លូវក្រាលបេតុងប្រវែង ៨៣,៤៤គ.ម ។ ការសាងសង់ផ្លូវក្រាលក្រួសក្រហមប្រវែង ១២គ.ម ។ ថែទាំផ្លូវជាលក្ខណៈខួប បានប្រវែង ១៩៥,៨៨គ.ម ។ ថែទាំផ្លូវជាលក្ខណៈប្រចាំ បានប្រវែង ៥០០,៥៣គ.ម ។ សាងសង់ស្ពានបេតុង បានចំនួន ០៦កន្លែង ។ សាងសង់លូកាត់ផ្លូវ បានចំនួន ៥៨កន្លែង ។ សាងសង់លូប្រអប់ ១៦កន្លែង ។ ចំពោះ ការងារផ្គត់ផ្គង់ទឹកស្អាតវិញបាន ៖ សាងសង់អណ្តូងស្នប់អាហ្វ្រីដេស បានចំនួន ២៦៩អណ្តូង ។ ជួសជុលអណ្តូងស្នប់អាហ្វ្រីដេស ចំនួន ១៥០អណ្តូង។ សាងសង់អាងទឹកភ្លៀងចំណុះ ៣៥ម៉ែត្រគូប ចំនួន ២អាង។ សាងសង់ស្ថានីយ៍ផលិតទឹកសុទ្ធ ចំនួន ៣៣កន្លែង។ ស្រះសហគមន៍ ចំនួន ៥កន្លែង។ ស្តារប្រឡាយស្រោចស្រព បានប្រវែង ១០.៤៧០ម៉ែត្រ ។

គម្រោង និងសកម្មភាពសាងសង់បង្គន់អនាម័យជនបទ ដែលក្នុងនោះ មានគម្រោងរាជរដ្ឋាភិបាល សហការជាមួយដៃគូអភិវឌ្ឍន៍ បានចំនួន ៨.២៧៧បង្គន់ ។ ទន្ទឹមនឹងនោះ មកដល់ពេលនេះ នៅតាមខ្នងផ្ទះប្រជាពលរដ្ឋ ដែលមានទឹកស្អាតប្រើប្រាស់ មានចំនួន ១៩៩.៩៧៩ខ្នងផ្ទះ ស្មើនឹង ៩១,០១% នៃអត្រាខ្នងផ្ទះ ដែលប្រជាពលរដ្ឋ មានទឹកស្អាតប្រើប្រាស់ នៅទូទាំងខេត្ត ។

## ៥.១-ការស្ថាបនា និងជួសជុល ដោយប្រើប្រាស់គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីបន្តនិរន្តរភាព ក្នុងការដឹកនាំគ្រប់គ្រង និងការអភិវឌ្ឍខេត្ត ពីអតីតអភិបាលខេត្ត រដ្ឋបាលខេត្តកំពង់ចាម បានគិតគូរយកចិត្តទុកដាក់ធ្វើការអភិវឌ្ឍខេត្តមួយនេះ ពីមួយឆ្នាំ ទៅមួយឆ្នាំឲ្យកាន់តែរីកចំរើន ជាបន្តបន្ទាប់។ ជាក់ស្តែង ក្នុងរយៈពេល ៥ឆ្នាំនេះ ខេត្តកំពង់ចាម បានធ្វើការអភិវឌ្ឍខេត្តរបស់ខ្លួន សម្រេចបាន៖

**ក-គម្រោងថវិការបស់សាលខេត្ត** ៖ ១.ផ្លូវបេតុង ២៩ខ្សែ ប្រវែង ៣៣.៧០០ម៉ែត្រ ផ្លូវក្រាលកៅស៊ូ AC ចំនួន ១១ខ្សែ ប្រវែង ៩.៦០១ម៉ែត្រ ផ្លូវក្រាលកៅស៊ូ DBST ចំនួន ៣៤ខ្សែ ប្រវែង ៧២.១៩៨ម៉ែត្រ ផ្លូវក្រាលក្រួសក្រហមចំនួន ៤៦ខ្សែ ប្រវែង ៨៩.៣៧១ម៉ែត្រ និងផ្លូវក្រាលល្បាយថ្មភ្នំចំនួន ២ខ្សែ ប្រវែង ២.១២៦ម៉ែត្រ ។ បន្ថែមពីនេះ ការសាងសង់អគារច្រកចេញចូលតែមួយ ចំនួន ៨កន្លែង អគារសាលាឃុំ ៥៣កន្លែង សាងសង់ជួសជុលលូ ១០កន្លែង ប្រវែង ១០.០៨៩ម៉ែត្រ សាងសង់ស្ពានចំនួន ២កន្លែង ប្រវែង ២២០,៥ម៉ែត្រ និងច្រាំងទន្លេ ០២កន្លែង ប្រវែង ១១៥ម៉ែត្រ ។

**ខ-គម្រោងថវិកាក្រុង-ស្រុក** ៖ ១.ផ្លូវបេតុង ១៥១ខ្សែ ប្រវែង ៤៧.៤០២ម៉ែត្រ ផ្លូវក្រាល ផ្លូវក្រាលក្រួសក្រហមចំនួន ៩ខ្សែ ប្រវែង ១២.៨៩៥ម៉ែត្រ និងផ្លូវក្រាលល្បាយថ្មភ្នំចំនួន ២ខ្សែ ប្រវែង ៤.១៥០ម៉ែត្រ ផ្លូវដី ១ខ្សែ ប្រវែង ៤៧០ម៉ែត្រ ស្តារប្រឡាយ ៤ខ្សែ ប្រវែង៧.៤៦៨ម៉ែត្រ។

**គ-គម្រោងថវិកាឃុំ-សង្កាត់** ៖ ១.ផ្លូវបេតុង ៤២៨ខ្សែ ប្រវែង ២២៣.១៩២ម៉ែត្រ ផ្លូវក្រាល ផ្លូវក្រាលក្រួសក្រហមចំនួន ៨៦ខ្សែ ប្រវែង ៣៥២.៥៣៤ម៉ែត្រ និងផ្លូវក្រាលល្បាយថ្មភ្នំ ចំនួន ៥៣ខ្សែ ប្រវែង ១៤០.៧៤៥ម៉ែត្រ ផ្លូវដី ៣៦ខ្សែ ប្រវែង ១៤១.៦០៨ម៉ែត្រ សាងសង់លូ

១៣ខ្សែ ប្រវែង ៤.៨៨៣ម៉ែត្រ ស្ពានប្រឡាយ ១១ខ្សែ ប្រវែង ៣២.៦៧៦ម៉ែត្រ និងជួសជុលទំនប់ទឹកចំនួន ១២ខ្សែ ប្រវែង ៣៣.៤៧៦ម៉ែត្រ។

**សរុបរួម** ផ្លូវក្រាលកៅស៊ូ AC ចំនួន ១១ខ្សែ ប្រវែង ៩.៦០១ម៉ែត្រ ផ្លូវក្រាលកៅស៊ូ DBST ចំនួន ៣៤ខ្សែ ប្រវែង ៧២.១៩៨ម៉ែត្រ ផ្លូវបេតុង ៦០៨ខ្សែ ប្រវែង៣០៤.២៩៤ម៉ែត្រ និងផ្លូវក្រាលគ្រួសក្រហម ១៤១ខ្សែ ប្រវែង ៤៥៤.៨០០ម៉ែត្រ។

## ៦-ការងារកសិកម្ម និងធារាសាស្ត្រ៖

### ៦.១-ការងារកសិកម្ម៖

ដំណាំស្រូវអនុវត្តបានចំនួន ១៤០.៧៣៦ ហិកតា ក្នុងឆ្នាំ២០១៨ កើនដល់ ១៤៧.៤២២ហិកតា ក្នុងឆ្នាំ២០២២ កើនប្រមាណជា ៤,៧% ចំណែកផលិតផលស្រូវផលិតបានចំនួន ៤៨៨.២៩២ តោនក្នុងឆ្នាំ២០១៨ កើនដល់ ៥៤៥.៥២១តោន ក្នុងឆ្នាំ២០២២ កើនប្រមាណ១១,៧%។

**តុល្យភាពស្បៀង៖**

ជារៀងរាល់ឆ្នាំខេត្តកំពង់ចាម ធានាបាននូវសន្តិសុខស្បៀងជានិច្ច ដោយក្នុងមួយឆ្នាំៗ ផលិតស្រូវបានចំនួន៤៧៤.៦០៤តោន គិតជាស្បៀងប្រមាណ ៣០៣.៧៤៦តោន មិនតែប៉ុណ្ណោះខេត្តកំពង់ចាម នៅសល់ស្បៀងជាអង្ករប្រមាណជា ១៦២.៣៤១តោន គិតជាស្រូវ ២៥៣.៦៥៨តោន សម្រាប់ការនាំចេញផងដែរ។

**-ដំណាំរយៈពេលខ្លី**

ដំណាំរយៈពេលខ្លីបានចូលរួមយ៉ាងសកម្មក្នុងលើកស្ទួយសេដ្ឋកិច្ចគ្រួសារ ដំណាំនេះអាចផលិតបានពី ២ទៅ៣ដងក្នុង១ឆ្នាំ ដូចជា ដំណាំបន្លែគ្រប់មុខ ដំណាំសណ្តែក ដំណាំឡូង និងថ្នាំជក់ជាដើម ដែលក្នុងឆ្នាំ២០១៨ ផលិតបានចំនួន ៦៣២.៣០៣តោន កើនដល់ ៧៣៦.៧១៣តោន ក្នុងឆ្នាំ២០២២។

**-ដំណាំរយៈពេលវែង**

ដូចជា ចេក ចន្ទី ស្វាយ ដូង ខ្នុរ ជាដើម ក្នុងឆ្នាំ២០១៨ផលិត បានចំនួន ១៦៦.៦០៤ តោន កើនដល់ ២៥៦.៦៨០ តោន ក្នុងឆ្នាំ២០២២។

**-ដំណាំកៅស៊ូ**

ដំណាំកៅស៊ូគឺជាដំណាំកសិ-ឧស្សាហកម្មមួយដ៏សំខាន់ ដែលបានបន្សល់ទុកកាលពីសម័យបារាំងមកម្លេះ។ ខេត្តកំពង់ចាម ចាប់តាំងពីឆ្នាំ២០១៤មក មកទល់ពេលនេះដំណាំកៅស៊ូ មានសរុបចំនួន ៣៣.២៤៥ហិចតា ដែលក្នុងនោះមាន ដំណាំកៅស៊ូគ្រួសារចំនួន ២៥.៤៨៧ហិចតានិងដំណាំកៅស៊ូក្រុមហ៊ុន ចំនួន ៧.៧៥៨ហិចតា។

**-ផលិតកម្មសត្វ**

អនុវិស័យសត្វ ត្រូវបានលើកម្ពស់និងកែលម្អរផងដែរ តាមរយៈការជំរុញឲ្យចិញ្ចឹមមានលក្ខណៈពាណិជ្ជកម្ម កែលម្អរពូជគោកូនកាត់ដែលមានទិន្នផលខ្ពស់។ លើសពីនេះ ការបណ្តុះបណ្តាលបច្ចេកទេសថ្មី បង្ហាត់សិប្បនិមិត្ត កសិដ្ឋានគំរូ បង្កើនការចាក់វ៉ាក់សាំងការពារជម្ងឺឆ្លងសត្វឲ្យបានយ៉ាងតិច៣០%ក្នុងមួយឆ្នាំ ដើម្បីកាត់បន្ថយអត្រាសត្វ

ឈើនិងស្លាប់ដោយសារជម្ងឺ ទន្ទឹមនេះការចិញ្ចឹមសត្វមានការកើនឡើងគួរឲ្យកត់សម្គាល់។ បច្ចុប្បន្ន យើងមានគោចំនួន ១៩៧.៤០១ក្បាល ក្របី ១៩.១៤១ក្បាល សេះ ១.០៧៧ ក្បាល ពពែ ៤.៥២៤ក្បាល ជ្រូក ១២៤.០៥៧ក្បាល ទា ៨៩៣.៦៣៥ក្បាលនិងមាន់ ២.០៧៧.៩៨៣ក្បាល។

-<u>ការចិញ្ចឹមត្រី</u>

ការជម្រុញវារីវប្បកម្មចិញ្ចឹមត្រី គឺជាគោលដៅ ដ៏សំខាន់ផងដែរ ក្នុងការកាត់បន្ថយពីការនេសាទពីធម្មជាតិ ដោយការបណ្តុះបណ្តាល ធ្វើបង្ហាញ ផ្តល់ពូជកូនត្រី... ។ល។ ដែលមានការកើនឡើងជាលំដាប់ពីមួយឆ្នាំ ទៅមួយឆ្នាំ ។ ជាក់ស្តែង ភោគផលត្រីត្រឹមឆ្នាំ២០២២នេះ ត្រីធម្មជាតិមានចំនួន **១៥.២៧០**តោន និងវារីវប្បកម្ម **២០.៥៥០** តោន ផងដែរ តម្រូវការទទួលទានត្រីប្រចាំឆ្នាំ **៥៨.៤៥៧**តោន និងខ្វះ **២២.៦៣៧**តោន។

## ៦.៧-<u>ប្រព័ន្ធធារាសាស្ត្រ</u>

ដោយមានការយកចិត្តទុកដាក់ ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយដៃគូអភិវឌ្ឍ ក៏ដូចជាក្រសួងស្ថាប័ននានា បានជម្រុញធ្វើឲ្យការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ដែលជាគន្លឹះដ៏ចម្បងមួយ ក្នុងការបង្កើននូវផលិតកម្មស្រូវ និងទប់ស្កាត់រាល់ហានិភ័យទាំងឡាយ ដែលបណ្តាលមកពីគ្រោះធម្មជាតិជាដើម។ យ៉ាងណាមិញ ផ្ទៃដីបង្កបង្កើនផលមួយចំនួន ត្រូវបានពង្រីកបន្ថែមតាមរយៈ ការកសាងនូវប្រព័ន្ធធារាស្រ្ត។ ផ្អែកតាមកិច្ចការនេះ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត បានយកចិត្តទុកដាក់ ក្នុងការកសាងនូវប្រព័ន្ធធារាសាស្ត្រក្នុងតំបន់ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេស ការងារបង្កបង្កើនផល របស់ប្រជាកសិករ។

បច្ចុប្បន្ន ប្រព័ន្ធធារាសាស្ត្រ នៅក្នុងខេត្តកំពង់ចាម មាន ៣ប្រភេទ គឺប្រភេទ តូច មធ្យម និងធំ សរុបចំនួន ២៤៨កន្លែង។ ប្រឡាយស្រោចស្រព ប្រវែង ២៧៥,៦៥គ.ម។ ប្រឡាយជើងក្អែបចំនួន ៣២៦.៨៣៩ម៉ែត្រ ស្ថិតនៅក្នុងស្រុកចំនួន៧ គឺស្រុកស្រីសន្ធរ ស្រុកព្រៃឈរ ស្រុកជើងព្រៃ ស្រុកចំការលើ ស្រុកស្ទឹងត្រង់ និងស្រុកបាធាយ។ ជួសជុលទំនប់ខ្វាត តូច មធ្យម និងធំ ចំនួន១៥កន្លែង, ស្តារប្រលាយមេ និងរង បានប្រវែង ២៧.៦៤៥ម៉ែត្រ សំណង់សិល្បៈការ តូចធំ សរុប ៤២១កន្លែង ក្នុងនោះសាងសង់ប្រព័ន្ធធារាសាស្ត្រព្រែកពោធិ៍ ក្នុងស្រុកស្រីសន្ធរ ចំនួន ០១កន្លែង ក្នុងនោះរួមមាន ការងារស្តារប្រឡាយបេតុងមេ និងរង ប្រវែង ៤៨,០២គីឡូម៉ែត្រ ស្តារប្រឡាយមេ ដី ប្រវែង ២៣,៣៣គីឡូម៉ែត្រ សាងសង់សំណង់សិល្បៈការ ១៥៣កន្លែង ដែលមានផ្ទៃដីស្រោចស្រពចំនួន ៧.៨៥០ហិចតា ។

សាងសង់ច្រាំងទន្លេមេគង្គ ក្រុងកំពង់ចាម បានប្រវែងសរុប ៣៧៨ម៉ែត្រ រៀបចំបាវខ្សាច់ (Geo Textile Bag) បានប្រវែង ៧.៣៤០ម៉ែត្រ ស្ថិតនៅស្រុកស្ទឹងត្រង់ កងមាស ស្រីសន្ធរ និង ស្រុកស្រីសន្ធរ ។ រៀបថ្មប្រេក ក្នុងសំណាញ់ តាមជើងទេព្រែកអន្លង់គគីរ បានប្រវែង ២៥០ម៉ែត្រ ឃុំព្រែកកុយ ស្រុកកងមាស ។ សាងសង់ប្រព័ន្ធធារាសាស្ត្រព្រែកពោធ៍ ចំនួន ១កន្លែង ស្ថិតក្នុងស្រុកស្រីសន្ធរួមមាន ៖ ស្តារប្រឡាយបេតុង មេ-និងរងប្រវែងសរុប ៤៨,០២គីឡូម៉ែត្រ ប្រឡាយមេដី ប្រវែងសរុប ២៣,៣៣គ.ម និងសំណង់សិល្បៈការ ១៥៣កន្លែង មានផ្ទៃដីស្រោចស្រព

ចំនួន ៧.៨៥០ហិកតា ។ ទន្ទឹមនឹងនោះ យើងមានប្រភពទឹក ទន្លេ អូរ បឹងបួរ និងប្រភពទឹកចេញ ដោយមានព្រែកមាន ចំនួន ៤១ព្រែក ផងដែរ ។

## ៧-រ៉ែ និងថាមពល

### ៧.១-ការងាររ៉ែ:

អាជីវកម្មរ៉ែសំណង់ សរុប មានចំនួន ៣៣ការដ្ឋាន និងស្ថានីយប្រេងឥន្ធនៈ៣១១កន្លែង ក្នុងនោះស្ថានីយឧស្ម័នឥន្ធនៈ ៤កន្លែង ស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ ២៩កន្លែង ។

### ៧.២-ការងារថាមពល អគ្គីសនី

ខេត្តកំពង់ចាមមាន អនុស្ថានីយ៍០២កន្លែង នៅឃុំក្រឡា ស្រុកកំពង់សៀម មានចំនួន សរុប ៣០០MW និងនៅឃុំព្រែកក់ ស្រុកស្ទឹងត្រង់ ចំនួន៥0MW

ក្រុមហ៊ុនផ្គត់ផ្គង់ និងចែកចាយអគ្គិសនី(រដ្ឋ និងឯកជន)មានចំនួន៤១ ក្រុមហ៊ុន ដែល មានដែនអាជ្ញាបណ្ណអគ្គិសនីគ្របដណ្តប់លើភូមិចំនួន៩២៣ភូមិ ស្មើនឹង១០០%។ ដោយឡែក ក្នុងឆ្នាំ២០២២ បានភ្ជាប់ចរន្តអគ្គិសនីចំនួន ២១០,០២៩ខ្នងផ្ទះ ដែលគ្របដណ្តប់ទូទាំង១០ ក្រុង-ស្រុក នៃភូមិចំនួន ៩២១ភូមិ លើ៩២៣ភូមិ ស្មើនឹង៩៩,៧៨% និងភូមិដែលមិនទាន់មាន បណ្តាញអគ្គិសនីប្រើប្រាស់ ចំនួន២ភូមិ។

## ៨-វិស័យឧស្សាហកម្ម និងសិប្បកម្ម ៖

### ៨.១-<u>ការងារឧស្សាហកម្ម និងសិប្បកម្ម</u>

មានរោងចក្រ សិប្បកម្មក្នុងខេត្ត ចំនួន១.៥៤៤មូលដ្ឋាន និងមានតម្លៃបរិមាណ ផលិតផល សរុបចំនួន ៧៣៤.៧១៤ លានរៀល មានកម្លាំងពលកម្មចូលបម្រើការងារសរុបចំនួន ៣៨.៤៩០នាក់ ស្រី ៣១.៨៤៥នាក់ ក្នុងនោះ

- រោងចក្រធុនធំ(វិនិយោគ) ចំនួន ២៧មូលដ្ឋាន
- រោងចក្រធុនមធ្យម ចំនួន ២៣មូលដ្ឋាន
- រោងចក្រធុនតូច ចំនួន ១៥៥មូលដ្ឋាន
- សិប្បកម្មមានចំនួន ១.៣៣៩មូលដ្ឋាន (ទុនក្រោម ៣.០០០ដុល្លារ មាន ចំនួន ៩៧៩មូលដ្ឋាន) ។

### ៨.២-<u>ការងារទឹកស្អាត</u>

ខេត្តកំពង់ចាម មានទឹកស្អាតផ្នែកសាធារណៈ ចំនួន ០១ មូលដ្ឋាន និងទឹកស្អាតផ្នែកឯក ជន ចំនួន ៦០ មូលដ្ឋាន សរុបចំនួន ៦១ មូលដ្ឋាន មានសមត្ថភាពផលិតទឹកស្អាតបានចំនួន **៩១៤ម$^{៣}$/ថ្ងៃ** មានវិសាលភាពគ្របដណ្តប់នៅទូទាំងខេត្តបានចំនួន ១០៧ឃុំ-សង្កាត់/១០៩ឃុំ/ សង្កាត់ ស្មើនឹង ៩៨.១៦% ដោយមានចំនួន ៨៨៣ ភូមិ /៩២៣ភូមិ ស្មើនឹង ៩៥.៦៦%។

ក្នុងរយៈពេល ៥ឆ្នាំ (២០១៨-២០២២) ការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋនៅទូទាំង ខេត្ត កើនបានចំនួន ២៧៦ភូមិ មានប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាតកើនបានចំនួន ៣៤,៧៤១ គ្រួសារ ក្នុងនោះ ទឹកស្អាតផ្នែកឯកជន បានពង្រីកដាក់បណ្តាញថ្មីកើនបានចំនួន ២៥៥ ភូមិ មានប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាតកើនបានចំនួន ២៧,៨១៨ គ្រួសារ និងអង្គភាព រដ្ឋាករទឹក បានពង្រីកបណ្តាញបន្ថែមកើនបានចំនួន ២១ ភូមិ មានប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាតកើន

បានចំនួន ៧,១០៣ គ្រួសារ។ សរុបបណ្តាញបំពង់ទឹកស្អាតចែកជូនដល់ប្រជាពលរដ្ឋបានចំនួន ៣០៤ ភូមិ /៩២៣ភូមិ ស្មើនឹង៧៦.២៧% ដោយមានប្រជាពលរដ្ឋចំនួន ៨៩,៤៤០ គ្រួសារ / ២៧៤,២៥៤ គ្រួសារ ស្មើនឹង ៣២.៦១% ។

## ៩-ការងារកែលម្អសោភ័ណ្ឌភាព ការគ្រប់គ្រងធនធានធម្មជាតិ និងទេសចរណ៍

### ៩.១-ការងារកែលម្អសោភ័ណ្ឌភាព

រដ្ឋបាលខេត្ត បន្តការយកចិត្តទុកក្នុងការអភិវឌ្ឍន៍ វឌ្ឍនភាពរបស់ខេត្តកំពង់ចាម រួមមាន កសាងជួសជុល កែលម្អសោភ័ណភាព និងពង្រីក ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត របស់ក្រុង-ស្រុក ជាពិសេសក្រុងកំពង់ចាម គឺជាក្រុងមួយ ដែលបានរៀបចំតុបតែងលម្អ ដោយភ្លើងពណ៌ សម្រាប់សោភ័ណពេលយប់ ជាការទាក់ទាញភ្ញៀវជាតិ អន្តរជាតិ សម្រាប់ហាត់ប្រាណ និងដើរកម្សាន្តផងដែរ។ ជាក់ស្តែង បានសាងសង់ផ្លូវ ប្រព័ន្ធលូបង្ហូរទឹកចេញពីក្រុង ការកែលម្អសួនច្បារនានា សាងសង់ប្រាំងទន្លេ ក្នុងក្រុងកំពង់ចាម បានប្រវែងសរុប ៣៧៨ម៉ែត្រ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀត។ លើសពីនេះ បានរៀបចំកែលម្អ សួនច្បារ និងសាងសង់ផ្លូវបេតុ ផ្លូវអ៊ុតកៅស៊ូ នៅក្នុងមូលដ្ឋាននៃស្រុកទាំង៩ ដើម្បីតភ្ជាប់ពីជនបទ ដល់ទីប្រជុំជន ដែលជួយសម្រួលក្នុងការដឹកជញ្ជូនកសិផលរបស់ប្រជាពលរដ្ឋ និងការប្រកបមុខរបរផ្សេងៗផងដែរ។

ដោយឡែក រដ្ឋបាលខេត្តកំពង់ចាម បានខិតខំប្រឹងប្រែងទាំងកម្លាំងកាយចិត្ត ក្នុងការចូលរួមអភិវឌ្ឍន៍មូលដ្ឋាន ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ នៃរាជរដ្ឋាភិបាលកម្ពុជា និងការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ឲ្យកាន់តែស៊ីជម្រៅ និងប្រសិទ្ធភាពបន្ថែមទៀត។

### ៩.២-វិស័យទេសចរណ៍ ៖

រមណីយដ្ឋាននៅក្នុងខេត្តកំពង់ចាម មានចំនួន ១១កន្លែង ក្នុងនោះ គ្រប់គ្រងដោយរដ្ឋចំនួន ០៥កន្លែង និងឯកជន០៦កន្លែង រួមមាន៖

- រមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ ០៤កន្លែង (នគរបាជ័យ ភ្នំហាន់ជ័យ ភ្នំដើងព្រៃ និងភ្នំប្រុស-ភ្នំស្រី)
- រមណីដ្ឋានធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ ០១កន្លែង (ប្រាសាទប្រជាតុទឹកធា)
- រមណីយដ្ឋានធម្មជាតិ ០៣កន្លែង (បឹងធំ កោះប៉ែន និងទំនប់តាកុច)
- រមណីយដ្ឋានកែច្នៃ ០៣កន្លែង (កសិ-ទេសចរណ៍ថ្មដាទឹកធា នាគខ្មៅ និងហាន់ជ័យបែមប៊ូរីស៊ត)

ជាមួយនេះ ហាងលក់វត្ថុអនុស្សាវរីយ៍ ចំនួន **០៧កន្លែង** មូលដ្ឋានអាជីវកម្ម មានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងមណ្ឌលកំសាន្តមនុស្សពេញវ័យ នៅទូទាំងខេត្ត មានសរុបចំនួន **៦៨២កន្លែង** ។ ក្នុងរយៈពេល ៥ឆ្នាំកន្លងទៅ នៅទូទាំងខេត្តកំពង់ចាម ទទួលបានភ្ញៀវមកទស្សនាកំសាន្តសរុបចំនួន ២.៥៥៧.៨៩៥នាក់ ក្នុងនោះ ទេសចរណ៍ជាតិចំនួន ២.៥០៩.៣២៩នាក់ និងភ្ញៀវអន្តរជាតិ ៤៨.៥៧៥នាក់ ។

## ១០-ការពង្រឹង និងជំរុញការផ្តល់សេវាសាធារណៈ

-រដ្ឋបាលខេត្តកំពង់ចាម បានជំរុញការផ្តល់សេវាជូនប្រជាពលរដ្ឋស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ដែលបានផ្ទេរមុខងារមករដ្ឋបាលថ្នាក់ក្រោមជាតិ សេវាដែលបាននឹងកំពុងផ្តល់ជូនប្រជាពលរដ្ឋនៅអង្គភាព ច្រកចេញចូលតែមួយរដ្ឋបាលខេត្ត មានចំនួន១៤វិស័យ បានផ្តល់សេវាជូនប្រជាពលរដ្ឋ សរុបចំនួន **១៣៥.២៣៦សេវា** និងនៅការិយាល័យច្រកចេញចូលតែមួយរដ្ឋបាលក្រុងស្រុក ១៤វិស័យ បានផ្តល់សេវាជូនប្រជាពលរដ្ឋ សរុបចំនួន **៦១៩.២៣១សេវា**។

-ឃុំ-សង្កាត់ទាំង១០៩ទូទាំងខេត្ត បានផ្តល់សេវាប្រចាំថ្ងៃ ពិសេសសេវាអត្រានុកូលដ្ឋានគ្រប់ប្រភេទ ជូនប្រជាពលរដ្ឋបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។

## ១១-ការងារចុះបញ្ជីដីធ្លី

### ក-ការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

-ក្បាលដីសរុបក្នុងទូទាំងខេត្តដែលត្រូវចុះបញ្ជីមានប្រមាណ ៩២៤.៤២១ក្បាលដី ស្មើនឹង ២៧៤.៣០៧គ្រួសារ។

ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) បានចុះបញ្ជីក្បាលដីចំនួន ១៩៩.១០៥ក្បាលដី បានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋបាន ចំនួន ២១០.០៧៥ប័ណ្ណ។

គិតត្រឹមបំណាច់ឆ្នាំ២០២២ អនុវត្តបានចំនួន ៧១៣.៥០០ក្បាលដី ស្មើនឹង ៧៧% នៅក្រុង-ស្រុកចំនួន ១០ ឃុំ-សង្កាត់ចំនួន ៩១ នៅសល់ចំនួន ២១០.៩២១ក្បាលដី ស្មើនឹង ២៣% នៅ ៥ស្រុក ១៨ឃុំ។

### ខ-ការងារដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីខេត្ត

ដោះស្រាយវិវាទដីធ្លីចាប់ពីឆ្នាំ២០១៨ មកដល់ឆ្នាំ២០២២ បញ្ចប់បានចំនួន ៧៤២ករណី ក្នុងនោះ៖

- បានសហការជាមួយរដ្ឋបាលខេត្តដោះស្រាយវិវាទដីធ្លីបញ្ចប់បានចំនួន ១៤ករណី
- ក្រុមការងារដោះស្រាយវិវាទដីធ្លីចល័តបាន៖
- ដោះស្រាយវិវាទដីធ្លីបានបញ្ចប់ ចំនួន ៦៣ករណី
- ប្រានចោលវិវាទដីធ្លី ចំនួន ៣៦ករណី
- ដកពាក្យបណ្តឹងវិវាទដីធ្លី ចំនួន ១៤ករណី
- បញ្ជូនពាក្យបណ្តឹងមកថ្នាក់ខេត្តចំនួន ០៥ករណី
- កំពុងដោះស្រាយវិវាទដីធ្លី ចំនួន ០៩ករណី ។
- ដោះស្រាយវិវាទដីធ្លីបញ្ចប់តាមគណៈកម្មការរដ្ឋបាលបានចំនួន ៦២៥ករណី ។។

## ១២-ការងារសុខាភិបាល

សមិទ្ធផលសុខាភិបាលសំរេចបាននៅក្នុងរយៈពេល៥ឆ្នាំបានមកពីការខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់មន្ត្រីបុគ្គលិកសុខាភិបាល នៅគ្រប់លំដាប់ថ្នាក់នៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ចាម គួបផ្សំនឹងការជួយឧបត្ថម្ភគាំទ្រនិងកិច្ចសហការប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ រួមមានរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ក្រោមការដឹកនាំពីសំណាក់រដ្ឋបាលខេត្ត ក្រសួងសុខាភិបាល និងជាពិសេស ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ដែលបានចាត់ទុកវិស័យសុខាភិបាលជាវិស័យអាទិភាពមួយនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ក្នុងការកែលំអរនូវស្ថានភាពសុខ ភាពរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលរស់នៅទីជនបទ។

**១-លទ្ធផលនៃការផ្តល់សេវាសុខភាពបន្តពូជ មាតា-ទារក និងកុមារ៖**

- អត្រានៃការសម្រាលកូន ដោយបុគ្គលិកសុខាភិបាលនៅមូលដ្ឋានសុខាភិបាល សម្រេចបាន ៨២% ។
- អត្រានៃការសម្រាលកូន ដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល សម្រេចបាន៩០% ។
- អត្រានៃកុមារអាយុក្រោមមួយឆ្នាំដែលបានទទួលថ្នាំបង្ការ DPT-HepB3 ១០០%
- អត្រានៃកុមារអាយុ៦-៥៩ខែបានទទួលគ្រាប់ថ្នាំជីវជាតិអា២ដូសក្នុងរយៈពេល១២ខែចុងក្រោយ (១ឆ្នាំ ២លើក)១០០ %។
- អត្រានៃកុមារអាយុក្រោមមួយឆ្នាំបានទទួលថ្នាំបង្ការជំងឺកញ្ជ្រឹល១០០%

**២-លទ្ធផលនៃការផ្តល់សេវាប្រយុទ្ធជំងឺឆ្លង៖**

- អត្រានៃអ្នកផ្ទុកមេរោគអេដស៍កំរិតសកម្ម បានទទួលឱសថប្រឆាំងមេរោគអេដស៍ច្រើនមុខ បាន៩៦%
- អត្រានៃអ្នកផ្ទុកមេរោគអេដស៍ប្រើឱសថប្រឆាំងមេរោគ អេដស៍នៅរស់ក្រោយការព្យាបាលរយៈពេល១២ខែ ស្មើនឹង ៩៦% ។
- អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង ៧២%
- ចំនួនករណីគ្រុនចាញ់ដែលបានព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈស្មើនឹង ០.០២នាក់ ក្នុងចំណោមប្រជាជន១.០០០នាក់ ។
- អត្រាស្លាប់ដោយជំងឺគ្រុនឈាមបានរាយការណ៍ដោយសុខាភិបាលសាធារណៈ ស្មើនឹង ០ភាគរយ

**៣-លទ្ធផលនៃការពង្រឹងប្រព័ន្ធសុខាភិបាល៖**

- អត្រាប្រើប្រាស់គ្រែ ស្មើនឹង ៥៦.៩២ភាគរយ
- រយៈពេលមធ្យមនៃការសំរាកព្យាបាល(ចំនួនថ្ងៃ) ស្មើនឹង ៣.៦៧ភាគរយ
- ចំនួនពិនិត្យពិគ្រោះជំងឺក្រៅ (ករណីថ្មី )ស្មើនឹង ៥៥៩.០៩៩ ករណី
- ចំនួនករណីជំងឺសំរាកពេទ្យ ស្មើនឹង ៤១.២៤៤ ករណី

**៤-ការគ្រប់ដណ្តប់នៃមូលនិធិសមធម៌៖**

- ចំនួនប្រើប្រាស់មូលនិធិសមធម៌នៅមន្ទីរពេទ្យខេត្ត ស្មើនឹង ៦.២៩៨ ករណី
- ចំនួនប្រើប្រាស់មូលនិធិសមធម៌នៅមន្ទីរពេទ្យបង្អែកស្រុកស្មើនឹង ១០.៦៨៧ ករណី
- ចំនួនប្រើប្រាស់មូលនិធិសមធម៌នៅមណ្ឌលសុខភាព ស្មើនឹង ៧៦.៥២៧ករណី

**៥-អំពីស្ថានភាពនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩៖**

ក្នុងកាលៈទេសៈនៃការរាតត្បាតនៃជម្ងឺកូវីដ-១៩ជាសាកល ខេត្តកំពង់ចាម បានឃើញករណីវិជ្ជមានកូវីដ-១៩ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២០ បន្ទាប់ពីការមកដល់នៃនាវាទេសចរ

ឈ្មោះ Viking cruise journey ដោយបានរកឃើញស្ត្រីជនជាតិអង់គ្លេស វ័យ ៦៥ឆ្នាំម្នាក់ និងបានរកឃើញជាបន្តបន្ទាប់ករណីវិជ្ជមានកូវីដ-១៩ សរុបចំនួន១៦រូប។ ជាមួយគ្នានេះ ខេត្ត ក៏បានទទួលរងផលប៉ះពាល់ពីព្រឹត្តិការណ៍០៣វិច្ឆិកា ព្រឹត្តិការណ៍ ២៨វិច្ឆិកា ព្រឹត្តិការណ៍ សាមុគសាខន នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ និងចុងក្រោយក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ត្រូវបានបិទបញ្ចប់កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ កន្លងទៅនេះជារួម បានរកឃើញ ករណីវិជ្ជមាន ចំនួន ៨.៦២៧នាក់ (ស្រី ៥.១៩០នាក់) ក្នុងនោះ អ្នកជំងឺជាសះស្បើយ ចំនួន ៨.២៨៥នាក់ (ស្រី ៤.៩៨០នាក់) អ្នកជំងឺស្លាប់ដោយសារជំងឺកូវីដ-១៩ ចំនួន ២១៥នាក់ (ស្រី ១៣២ នាក់) និងអ្នកស្លាប់សរុបដោយបញ្ហាផ្សេង ចំនួន ១២៧ នាក់ (ស្រី៧៧នាក់) ។

ដោយអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ** រដ្ឋបាលខេត្ត បាន ចាត់ចែងរៀបចំប្រែក្លាយសណ្ឋាគារមេគង្គ ទៅជាមន្ទីរពេទ្យសម្រាប់ព្យាបាលជំងឺកូវីដ-១៩ និងត្រូវបានប្រសិទ្ធិនាមជាមន្ទីរពេទ្យមេគង្គកំពង់ចាម មានគ្រែចំនួន ២៧០គ្រែ ក្នុងនោះគ្រែ ICU ៩០គ្រែ។ មន្ទីរពេទ្យនេះបានស្រោចស្រង់អាយុជីវិតប្រជាពលរដ្ឋខេត្តកំពង់ចាម និងប ណ្តាខេត្តនានាជុំវិញ ជាច្រើនពាន់នាក់។ ក្នុងអំឡុងពេលនៃដំណាក់កាលឆ្លងរីករាលដាលចូល ក្នុងសហគមន៍ ក្នុងព្រឹត្តិការណ៍២០កុម្ភៈ រដ្ឋបាលខេត្ត បានរៀបចំវិទ្យាល័យព្រះសីហនុ ក្រុង កំពង់ចាម ជាកន្លែងព្យាបាលកម្រិតស្រាល បន្ទាប់ពីបើកបរវេសនកាល រដ្ឋបាលខេត្ត ក៏បាន រៀបចំឃ្លាំងពាណិជ្ជកម្ម នៅស្រុកកំពង់សៀម ប្រើប្រាស់បានមួយរយៈពេល មានគ្រែ ចំនួន ៥៩៨គ្រែ គ្រែICU ចំនួន ២០គ្រែ។ ទន្ទឹមនេះ មណ្ឌលចត្តាឡីស័កដែលរៀបចំដោយរដ្ឋបា លខេត្ត និងស្រុកមានចំនួនសរុប ១១មណ្ឌល ត្រូវបានបិទបញ្ចប់ទាំងស្រុងត្រឹមថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០២១។ជាមួយនេះបានសាងសង់ ស្ថានីយ៍ផលិតអុកស៊ីសែន ដែលជាអំណោយដ៏ ថ្លៃថ្លារបស់ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** ដែលក្នុង១ថ្ងៃអាចផលិតបានចំនួន ជាង២០០ដប ដើម្បីជួយសង្គ្រោះអ្នកជំងឺកូវីដ-៩កម្រិតធ្ងន់។ ហើយឯកឧត្តម បានឧបត្ថម្ភ គ្រែអ្នកជំងឺចំនួន ២០០គ្រែ ទន្ទឹមនេះ ឯកឧត្តម **ហ៊ុន ម៉ានិត** ក៏បានឧបត្ថម្ភគ្រែអ្នកជំងឺចំនួន ៥០០គ្រែ និងឧបត្ថម្ភ Rapid test មួយចំនួន។

**<u>អំពីការផ្តល់វ៉ាក់សាំងកូវីដ-១៩</u>**

បើទោះបីស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាសកលដែលផ្តល់ផលប៉ះ ពាល់ដល់សេដ្ឋកិច្ច និងសង្គម តែព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបគតិបណ្ឌិត របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំគៀងគរស្វែងរកវ៉ាក់សាំងចាក់ជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃសំដៅបង្កើតភាពស៊ាំ នៅក្នុងសហគមន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់។ តាមរយៈ ដាក់ចេញនូវ «យុទ្ធនាការជាតិ ចាក់វ៉ាក់សាំង» ជូនដល់ប្រជាជនកម្ពុជា ក្នុងនោះប្រជាជនខេត្តកំពង់ចាម បានចាក់វ៉ាក់សាំង កូវីដ-១៩ ដូសមូលដ្ឋាន បានចំនួន ៨៨១.៧៧៨នាក់ ស្មើនឹង ៩០,៨២% ដូសជំរុញាក់ដូសទី ៣( ដូស ជំរុញ) ចំនួន ៥១១.៦២៣នាក់ ស្មើនឹង៥២,៦៩% ដូសទី៤ ចំនួន ២១០.៨៨០ នាក់ ស្មើនឹង២១,៧២% ដូសទី៥ ចំនួន ៦៧.០០៣នាក់ ស្មើនឹង៦,៩០%។ ហើយនៅថ្ងៃទី ០៩ ខែមករា ឆ្នាំ២០២៣កន្លងទៅនេះ រដ្ឋបាលខេត្តកំពង់ចាម បានចាប់ផ្តើមអនុវត្តចាក់វ៉ាក់

សាំងកូវីដ-១៩ ដូសទី៦ ជូនដល់មន្ត្រីរាជការ កម្លាំងប្រដាប់អាវុធនិងប្រជាពលរដ្ឋ បានចំនួន ២.៩១១នាក់ ស្មើនឹង០,៣១%។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមយកឱកាសនេះ ក្នុងនាមប្រជាពលរដ្ឋខេត្តកំពង់ចាមទាំងមូល សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម ឯកឧត្តម **ហ៊ុន ម៉ានិត** ដែលជានិច្ចកាលបានជួយឧបត្ថម្ភគាំទ្រ និងផ្តល់អនុសាសន៍ដឹកនាំក្នុងការងារគ្រប់គ្រង និងប្រយុទ្ធប្រឆាំងនឹងការឆ្លងរីករាលនៃជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យកាលពីពេលកន្លងទៅនេះ។

### ១៣-ការអនុវត្តកម្មវិធីជំនួយសង្គម នៃគោលនយោបាយគាំពារសង្គម

ក្នុងនិតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយគាំពារសង្គម សំដៅជួយលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ដែលមានហានិភ័យខ្ពស់ សំដៅកាត់បន្ថភាពក្រីក្រឱ្យបានជាអតិបរិមា។ ជាលទ្ធផល ខេត្តកំពង់ចាម សម្រេចបាន ដូចខាងក្រោម៖

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំ បានចុះឈ្មោះអ្នកទទួលផល សរុបចំនួន **៩,១៨៦**នាក់ ក្នុងនោះ ស្ត្រីមានផ្ទៃពោះ ចំនួន **៦,៩៤៨**នាក់ និងកុមារ ចំនួន **២,២៣៨**នាក់ និងអ្នកទទួលផលបានមកអនុវត្តលក្ខខណ្ឌ នៅតាមមណ្ឌលសុខភាព ចំនួន **១៦,១៩៤**ករណី កុមារចំនួន **៤៧,២៨៨**ករណី និងសម្រាលកូន **៧,៨៥៨** នាក់ ស្មើនឹងទឹកប្រាក់សរុប **៤,១៦៣,៦៨០,០០០** រៀល ។
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជម្ងឺកូវីដ-១៩ មកដល់ជុំទី១២ លើកទី០៣ ខែធ្នូ ឆ្នាំ២០២៣នេះ អ្នកទទួលផលបានមកផ្ទៀងផ្ទាត់ និងបើកផ្តល់ប្រាក់ជូនគ្រួសារក្រីក្រ សរុប **៤៨,៣៥៤** គ្រួសារ ស្មើនឹងទឹកប្រាក់ **២៣៩,១៦៣,៩៦៤,០០០** រៀល ។
- កម្មវិធីជំនួយសង្គមជាសាច់ប្រាក់សម្រាប់គ្រួសារដែលមានអ្នកឆ្លង និងគ្រួសារដែលមានអ្នកស្លាប់ ដោយជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ សរុបចំនួន **៧៦០** គ្រួសារ ស្មើនឹងទឹកប្រាក់ **១៣២,៤៨៤,៩០០**រៀល ក្នុងនោះ គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ ចំនួន **៦៤០**គ្រួសារ ស្មើនឹងទឹកប្រាក់ **២៦៩,៧៤៤,៦០០**រៀល និងគ្រួសារដែលមានអ្នកស្លាប់ដោយជំងឺកូវីដ-១៩ ចំនួន **១២០** គ្រួសារ ស្មើនឹងទឹកប្រាក់ **៨៤,៨២៧,៥០០**រៀល។
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេល មានសម្ពាធអតិផរណា ចំនួន**១១,៩៥៨** នាក់ ស្មើនឹងទឹកប្រាក់ **១,៥៦៩,៧០១,៤០០** រៀល និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ដោយទឹកជំនន់ ចំនួន **៨,១៧៩** នាក់ ស្មើនឹងទឹកប្រាក់ **១,២៣៤,៩៦០.០០០**រៀល។

## III-សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ រដ្ឋបាលខេត្តកំពង់ចាម បានចូលរួមអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ពិសេសកម្មវិធីកំណែទម្រង់ស្នូលទាំងបី គឺកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឲ្យមានភាពប្រទាក់ក្រឡាស៊ីចង្វាក់គ្នា ជាមួយគ្នានោះដែរ រដ្ឋបាលខេត្ត បានរៀបចំ និងអនុវត្តនូវគោលការណ៍ និងផែនការសកម្មភាពជាប្រចាំ ដូចជាការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ (២០២០ ដល់២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត ដើម្បីបញ្ចូលគម្រោង ដែលជាអាទិភាពសម្រាប់ធ្វើការអនុវត្តន៍ ឲ្យស្របតាមកម្មវិធីថ្នាក់ជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ លើសពីនេះ រដ្ឋបាលខេត្ត នៅបន្តតាមដានត្រួតពិនិត្យថែទាំ និងវាយតម្លៃលើគម្រោងខេត្ត ដែលជាសមិទ្ធផលនានា អនុវត្តកន្លងមករួមទាំងហេដ្ឋាចរនាសម្ព័ន្ធ រូបវន្ត និងអរូបវន្ត។

ក្នុងកែទម្រង់រដ្ឋបាលសាធារណៈ រដ្ឋបាលខេត្តបានខិតខំពង្រឹង និងលើកកម្ពស់ជាប្រចាំនូវគុណភាព ប្រសិទ្ធភាព នៃការផ្តល់សេវាធារណៈ រួមទាំងការផ្តល់សេវរដ្ឋបាលនានា ជូនប្រជាពលរដ្ឋ ការគាំទ្រនៃកែទម្រង់មន្ត្រីរាជការស៊ីវិល ពង្រឹងសមត្ថភាពមន្ត្រីគ្រប់លំដាប់ថ្នាក់ ដើម្បីបំពេញការងារ ដោយស្របតាមការកំណែទម្រង់របស់រាជរដ្ឋាភិបាល និងតម្រូវការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ លើសពីនេះ ការគាំទ្រលើតួនាទី ភារកិច្ច ក្នុងរចនាសម្ព័ន្ធ របស់រដ្ឋបាលក្រុង ស្រុក ក្រោយពីការធ្វើសមារណកម្មការិយាល័យជំនាញ ជុំវិញសាលាក្រុង ស្រុក ឲ្យមកចំណុះរដ្ឋបាលក្រុង ស្រុក សំដៅធ្វើការកែលម្អ និងពង្រឹងស្ថាប័ន។ ទន្ទឹមនេះ សាលាឃុំ សង្កាត់ អង្គភាពច្រកចេញចូលតែមួយតាមក្រុង-ស្រុក បានសាងសង់គ្រប់ចំនួន និងបានដាក់ឱ្យដំណើរការ ការងារផ្តល់សេវា ជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ជាមួយគ្នានេះរដ្ឋបាលខេត្តក៏បានសាងសង់សំណង់លំអរសោភ័ណ្ឌភាពក្រុងកំពង់ចាម គឺរូបសំណាក់ព្រះឥន្ទ្រគង់លើដំរីឯរាវ័ណ នៅសួនច្បារមាត់ទន្លេ និងសំណង់វិមានឯករាជ្យដ៏ល្អប្រណិតនៅទន្លេអុំដែលបង្កប់អត្ថន័យជាប្រវត្តិសាស្ត្រ។

ក្រៅពីការយកចិត្តទុកដាក់ក្នុងការផ្តល់សេវាតម្រូវការ និងសេវាសំណូមពរនានា ដើម្បីចូលរួមអភិវឌ្ឍន៍ខេត្ត និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រដ្ឋបាលខេត្ត បានយកចិត្តទុកដាក់អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការណែនាំនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ក្រសួងសុខាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបង្ការទបស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ឲ្យបានប្រសិទ្ធខ្ពស់។ ជាក់ស្តែងគណៈកម្មការខេត្តប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងអាជ្ញាធរពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយខ្លឹមសារសំខាន់ៗតាមវិទ្យុ ទូរទស្សន៍ តាមប្រព័ន្ធឧគ្ឃោសនាសព្ទ តាមវេទិកាផ្សេងៗ និងចុះអប់រំតាមខ្នងផ្ទះជូនប្រជាពលរដ្ឋ ឲ្យមានការយល់ដឹងកាន់តែខ្ពស់ ក្នុងការការពារខ្លួនកុំឲ្យឆ្លងជំងឺកូវីដ-១៩ និងអនុវត្តតាមវិធានការ "**៣កុំ ៣ការពារ**" ឲ្យបានម៉ឺងម៉ាត់។

ទាំងអស់នេះ ផ្តើមចេញកត្តាសន្តិភាព ស្ថេរភាពនយោបាយ ដែលជាសសរស្តម្ភដ៏រឹងមាំ សម្រាប់ការអភិវឌ្ឍន៍ និងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ វិនិយោគគិន អ្នកទេសចរ អន្តរជាតិ ក្រោមការដឹកនាំប្រកបដោយភាពប៉ិនប្រសប់ និងឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ ជាមួយនេះ ការតម្លើងប្រាក់បៀវត្ស បេឡាជាតិរបបសន្តិសុខសង្គម ធ្វើឱ្យមន្ត្រីមានឆន្ទៈខិតខំបំពេញការងារផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយគុណភាព និងប្រសិទ្ធភាព។

កត្តាសន្តិភាព ជាមូលដ្ឋាននៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យផ្សេងៗទៀត ក្នុងនោះសមិទ្ធផលជាប្រវត្តិសាស្ត្រដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ជូនប្រជាពលរដ្ឋខេត្តកំពង់ចាម ដែលរួមមាន៖ ស្ពានឆ្លងកាត់ទន្លេមេគង្គស្ទឹងត្រង់-ក្រូចឆ្មារ ផ្លូវជាតិលេខ ៧១ ផ្លូវលេខ៧០បេ សាលារៀន និងសមិទ្ធផលនានាទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រក្នុងខេត្ត បន្ថែមពីនេះសមិទ្ធផលដ៏ថ្មីស្រឡាងមួយទៀតនឹងចាប់ផ្តើមស្ថាបនាក្នុងឆ្នាំ ២០២៣ គឺប្រព័ន្ធលូរំដោះទឹកកង្វក់ និងស្ថានីយចំរោះទឹកកង្វក់ដែលមានតម្លៃប្រមាណជា ៣០លានដុល្លា និងផ្លូវកៅស៊ូបេតុង សំណង់អគារសាធារណៈនានា ជាពិសេស ការពង្រីក និងលើកម្រិតគុណភាពកំណាត់ផ្លូវជាតិលេខ ៧ ជា៤គន្លង ចាប់ពីរង្វង់មូលស្គន់ ស្រុកជើងព្រៃ រហូតដល់គល់ស្ពានគីហ្សូណា ក្រុងកំពង់ចាម មានប្រវែង ៤៥,៤៩គីឡូម៉ែត្រ នឹងគ្រោងចំណាយថវិកាសរុបជាង ១១៧លានដុល្លារ ដែលជាការតភ្ជាប់ដ៏មានសារៈសំខាន់ មិនត្រឹមតែក្នុងខេត្តកំពង់ចាមទេ តែមានការតភ្ជាប់ទៅកាន់ខេត្តជាច្រើនផ្សេងទៀត ដែលជាសសៃឈាមសេដ្ឋកិច្ចដ៏មានសក្តានុពលនៅក្នុងខេត្តកំពង់ចាម៕

(**វេទិកាសំណួរ-ចម្លើយរបស់អគ្គសន្និសីទ**)